96

94/14

10/Sept/2018

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គាំងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តស្វាយរៀង

សាលាដំបូងខេត្តស្វាយរៀង
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ២៧៧ ចុះថ្ងៃទី១០
ខែ សីហា ឆ្នាំ ២០១៧
សាលក្រមព្រហ្មទណ្ឌ
លេខ:២០០ (យ) ចុះថ្ងៃទី
២៣ខែ សីហា ឆ្នាំ ២០១៨

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តស្វាយរៀងកាលពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០១៨ និងប្រកាសសាលក្រមនៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៨ ដោយមានសមាសភាពដូចតទៅ:

### ក្រុមប្រឹក្សាជំនុំជំរះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តស្វាយរៀង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តស្វាយរៀង

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ២៧៧ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៧ ដែលមានជនជាប់ចោទ:

១-ឈ្មោះ[redacted]សុជាតិ អាយុ ៣៥ឆ្នាំ ភេទ ប្រុស ជាតិ ខ្មែរ របររកស៊ីបើកបររថយន្តតាក់ស៊ី មានទីកន្លែងកំណើតនិង[redacted] ខេត្តស្វាយរៀង។ ឪពុកឈ្មោ[redacted](រ) ម្តាយឈ្មោះ [redacted](រ)ប្រពន្ធឈ្មោះ [redacted]មានកូន ២នាក់ ទោសពីមុនគ្មាន ជានីតិជន (ចាប់ឃាត់ខ្លួនថ្ងៃទី ០៨-០៨-២០១៧ និងឃុំខ្លួនថ្ងៃទី ១១-០៨-២០១៧) ។ មេធាវីការពារឲ្យជនជាប់ចោទលោក ឈាវ វន្ណា និង លោក ប្រាក់ ភិន ។

២-ឈ្មោ[redacted]សូនី អាយុ ៣២ឆ្នាំ ភេទ ប្រុស ជាតិ ខ្មែរ របររកស៊ីបើកបររថយន្តតាក់ស៊ី មានទីកន្លែងកំណើតនិង[redacted] ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង។ ឪពុកឈ្មោះ[redacted]) ម្តាយឈ្មោះ [redacted](រ)ប្រពន្ធឈ្មោះ[redacted] មានកូន ២នាក់ ទោសពីមុនគ្មាន ជានីតិជន (ចាប់ឃាត់ខ្លួនថ្ងៃទី ០៨-០៨-២០១៧ និងឃុំខ្លួនថ្ងៃទី ១១-០៨-២០១៧) មេធាវីការពារឲ្យជនជាប់ចោទលោក [redacted]សម្បត្តិ ។

ជាប់ចោទពីបទ: ឃាតកម្មដោយមានទារុណកម្ម និងអំពើរលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិតា៧ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ ។

### ដើមបណ្តឹងរដ្ឋប្បវេណី

Scanned with CamScanner

១-ឈ្មោះ [redacted] ស្រីឡូត ភេទ ស្រី អាយុ ៣៥ឆ្នាំ ជាតិ ខ្មែរ របររកស៊ីធ្វើស្រែ មានទីលំនៅសព្វថ្ងៃនៅភូមិដូនមៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ(មេធាវីលោកស្រីអ៊ុក ស៊ីណាកេត)

២-ឈ្មោះ [redacted] សុវណ្ណ ភេទ ប្រុស អាយុ ៣៨ឆ្នាំ ជាតិ ខ្មែរ របររកស៊ីធ្វើស្រែ មានទីលំនៅសព្វថ្ងៃនៅភូមិដូនមៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ(មេធាវីលោកស្រីអ៊ុក ស៊ីណាកេត)

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ: ២៤៥ អយ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តស្វាយរៀង ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជំរះលេខ: ២៤៤២ តក, ព្រទ ១៧ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧ របស់ចៅក្រមស៊ើបសួរ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ: ២៩៧ ដសរ/១៧ ចុះថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០១៧ របស់ប្រធានសាលាដំបូងខេត្តស្វាយរៀង ។

**ដំណើររឿងហេតុមានដូចតទៅ**

កាលពីថ្ងៃទី១២ ខែ មករា ឆ្នាំ ២០១៨ សមត្ថកិច្ចជំនាញនគរបាលព្រហ្មទណ្ឌខេត្តស្វាយរៀង បានទទួលពាក្យបណ្តឹងពីឈ្មោះ [redacted] សុវណ្ណ ប្តឹងឲ្យសមត្ថកិច្ចជួយស្រាវជ្រាវរកកូនស្រីឈ្មោះ [redacted] សុម៉ាលីន ដែលបានបាត់ខ្លួនកាលពីថ្ងៃទី ០៣-០៨-២០១៧ នៅពេលដែលកូនស្រីខ្លួនត្រឡប់មកពីផ្ទះនៅខេត្តព្រះវិហារ មកធ្វើការនៅខេត្តស្វាយរៀងវិញ នៅពេលមកដល់ចំណុចផ្សារជីភូក៏បាត់ដំណឹង ។ ក្រោយទទួលបានពាក្យបណ្តឹងសមត្ថកិច្ចបានធ្វើការស្រាវជ្រាវកំណត់មុខសញ្ញានឹងឈានទៅដល់ការឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] សុជាតិ ដើម្បីធ្វើការសាកសួរ នៅចំពោះមុខសមត្ថកិច្ចឈ្មោះ [redacted] សុជាតិ បានឆ្លើយសារភាពថា ខ្លួនពិតជាបានប្រព្រឹត្តអំពើរំលោភសម្លាប់នារីរងគ្រោះនៅចំណុចភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី ០២-០៨-២០១៧ នោះពិតមែន ដោយធ្វើសកម្មភាពជាមួយបក្ខពួកម្នាក់ទៀតឈ្មោះ [redacted] សូនី ជាអ្នករត់តាក់ស៊ីដូចគ្នា ។ ក្នុងពេលនោះសមត្ថកិច្ចក៏បានធ្វើការឆែកឆេរក្នុងរថយន្តម៉ាកហាយលែនឌ័រពណ៌សជារបស់ឈ្មោះ [redacted] សុជាតិ រកឃើញខ្សែកកាឡែចំនួន ១ខ្សែ នឹងជញ្ជៀនដាំត្បូងពណ៌សកាឡែ១វង់ របស់ជនរងគ្រោះនៅក្នុងរថយន្តទៀតផង ។ នៅក្នុងថ្ងៃដដែលនោះដោយមានកិច្ចសហការជាមួយកំលាំងជំនាញនគរ បាលព្រហ្មទណ្ឌកំរិតធ្ងន់នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ក៏បានឃាត់ខ្លួនជនសង្ស័យដែលជាបក្ខពួកម្នាក់ទៀតឈ្មោះ [redacted] សូនី នាំមកសាកសួរនឹងកសាងសំណុំរឿងបញ្ជូនមកអយ្យការចាត់ការតាមច្បាប់ ។

បានឃើញដីកាស្ថាពរលេខ:២៤៥ អ.យ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០១៧ បានសម្រេចចោទប្រកាន់លើឈ្មោះ [redacted] សុជាតិ និងឈ្មោះ [redacted] សូនី ពីបទ: ឃាតកម្មដោយមានទារុណកម្ម អំពើរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី០២-០៨-២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ និងបញ្ជូនជនជាប់ចោទឈ្មោះ [redacted] សុជាតិ និងឈ្មោះ [redacted] សូនី (នៅក្នុងឃុំ) នឹងសំណុំរឿងព្រហ្មទណ្ឌលេខ:២៧៧ ចុះថ្ងៃទី ១០-០៨-២០១៧ ព្រមទាំងវត្ថុ

Scanned with CamScanner

គាងនឹងបញ្ជីរាយនាមជនដែលជាប់ទាក់ទិនក្នុងរឿងនេះ ទៅសាលាដំបូងខេត្តស្វាយរៀង ដើម្បីជំនុំជំរះតាមច្បាប់ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted]សុជាតិ បានឆ្លើយបញ្ជាក់ក្នុងពេលសវនាការថា: កាលពីថ្ងៃទី ០២-០៨-២០១៧ វេលាម៉ោងជាង ២រសៀល ខ្លួនដឹកម៉ូយប្រុសៗចំនួន ៥នាក់នឹង ស្រីម្នាក់ចេញពីភ្នំពេញឆ្ពោះទៅបាវិត ។ ពេលមកដល់អ្នកលឿងក្បាលស្ពានខាងលិចខ្លួនបាន ដាក់ម៉ូយប្រុសៗចំនួន ២នាក់ចុះ នឹងបានជួបឈ្មោះ មុន្នី(ឈ្មោះពិត [redacted] សុនី)ដឹកម៉ូយមកដល់ក្រោយខ្លួនដែរដោយបើកឡានយឺតៗ ខ្លួនបានប្រាប់ឈ្មោះ មុន្នី(ឈ្មោះពិត [redacted] សុនី)ថា:មានស្រីស្អាតឯឈ្មោះ មុន្នី(ឈ្មោះពិត [redacted] សុនី)យកទៅ រួចក៏បង្ហួសឡានទៅមុនខ្លួន ។ នៅ ពេលខ្លួនមកដល់ផ្សារកអណ្ដើកខ្លួនបានដាក់ម៉ូយប្រុសៗ២នាក់ទៀតចុះ ខ្លួនក៏បើកឡានមកដល់ស្វាយរៀងឈ្មោះ មុន្នី(ឈ្មោះពិត [redacted]សុនី)ទូរសព្ទ័មកប្រាប់ខ្លួនថាវានៅចាំមុខពេទ្យជីភូ តែលេខទូរសព្ទ័ដែលឈ្មោះ មុន្នី(ឈ្មោះពិត[redacted]សុនី)តេមករកខ្លួនក្នុងពេលនោះពុំមែនលេខ វាទេ(ចូលមកក្នុងទូរស័ព្ទខ្លួនលេខ[redacted])នៅពេលខ្លួនបើកឡានទៅដល់មុខពេទ្យជីភូ ខ្លួនដាក់ម៉ូយប្រុសម្នាក់ទៀតចុះ នៅសល់តែនារីម្នាក់ដែលទៅបាវិត ។ នៅពេលនោះឈ្មោះ មុន្នី(ឈ្មោះពិត [redacted] សុនី)បានឡើងជិះឡានខ្លួនបាំងខាងក្រោយជាមួយនារីដែលជាជនរងគ្រោះ ហើយឈ្មោះមុន្នី(ឈ្មោះពិត [redacted] សុនី)ប្រាប់ខ្លួនថា: បើកទៅយកពួកម៉ាកវានៅកែងមេសថ្ងក(សាលាស្រុកចន្ទ្រា) ពេលខ្លួនបើកឡានទៅដល់ឈ្មោះ មុន្នី ប្រាប់ថា ពួកម៉ាកវាចាំយូរ ទៅបាត់ហើយ ខ្លួនក៏បើកឡានមកបាវិតវិញតាមសង្កាត់បាទី ពេលខ្លួនបើកឡានទៅដល់ថ្នល់ កែង(ផ្លូវមួយទៅសង្កាត់ប្រាសាទនឹងមួយទៅសង្កាត់បាទី)ហួសថ្នល់កែង ១០០មឈ្មោះ មុន្នី (ឈ្មោះពិត[redacted] សុនី)ចាប់ផ្ដើមធ្វើសកម្មភាពចាប់ដៃជនរងគ្រោះចងទៅក្រោយ រួចរំលោភជនរងគ្រោះនៅក្នុងឡានខ្លួននៅពេលខ្លួនបើកឡានចូលទៅដល់ផ្លូវចូលរោងចក្រយីងមេខ័រ ឈប់ឡានអែបខាងកើតបែរមុខទៅជើងឈ្មោះ មុន្នី ចុះពីឡានខ្លួនឡើងទៅរំលោភម្ដងតែខ្លួន ឃើញជនរងគ្រោះដេកសន្លប់ ខ្លួនស្រាយកន្សែងចេញពីដៃជនរងគ្រោះ នឹងប្រាប់ឈ្មោះ មុន្នី(ឈ្មោះពិត [redacted] សុនី)ថា កុំសម្លាប់គេនៅពេលនោះឈ្មោះ មុន្នី(ឈ្មោះពិត [redacted] សុនី)បានឆក់យកកន្សែងពីដៃខ្លួនទៅទាក់កជនរងគ្រោះនឹងថាកុំទុករួចក៏ទាញជនរងគ្រោះទំលាក់ចេញពីក្នុងឡានអូសយកទៅចោលក្នុងស្រែមានទឹកតិចៗប្រហែល ៦ម៉ែត្រ ពីឡានដោយមានដុំថ្មដាក់សង្កត់ពីលើផង។ នៅពេលអូសសពជនរងគ្រោះទៅចោលរួចហើយខ្លួនបើកឡានចេញមកតាមផ្លូវរោងចក្រយីងមេខ័រ បានប្រហែល២០០ម៉ែត្រឈ្មោះ មុន្នី(ឈ្មោះពិត [redacted] សុនី)ក៏ជំលាក់ឥវ៉ាន់ជនរងគ្រោះចោលតាមទ្វារឡានខាងក្រោយ នឹងជិះឡានជាមួយគ្នាមកដល់ជីភូបែកគ្នារៀងៗខ្លួនតែម្ដង ។ លុះដល់ថ្ងៃទី ០៨-០៨-២០១៧ ខ្លួនទៅដឹកម៉ូយនៅបាវិតឃើញឈ្មោះ មុន្នី(ឈ្មោះពិត[redacted]សុនី)បានម៉ូយទៅភ្នំ ពេញមុនខ្លួន ជាមួយគ្នានោះខ្លួនក៏ត្រូវបានសមត្ថកិច្ចស្ទាក់ឡានឃាត់នៅត្រង់រូបសឹងនាំមកសាកសួរនៅសមត្ថកិច្ចនគរបាលខេត្តស្វាយរៀង និងបានបញ្ជូនខ្លួនជាបន្តបន្ទាប់មកតុលាការ ឃុំខ្លួនហូតដល់សព្វថ្ងៃ ។ ចំពោះខ្សែកនឹងជញ្ជៀនជនរងគ្រោះពេលព្រឹកខ្លួនបោសឡានឃើញនៅ

Scanned with CamScanner

ក្នុងឡានខ្លួន១យកទុកក្នុងប្រអប់ឡានខាងមុខនឹងត្រូវសមត្ថកិច្ចឆែកឆេររកឃើញដកហូតពីខ្លួនតែម្តង ។

-ជនជាប់ចោទឈ្មោះ [redacted] សូនី បានឆ្លើយបដិសេធក្នុងពេលសវនាការថា: កាលពីថ្ងៃទី ០២-០៨-២០១៨ វេលាម៉ោង ៨ព្រឹក ខ្លួនទទួលទូរស័ព្ទរបស់អ្នកទាក់ទងម៉ូយនៅ បាវិត នឹងថាឲ្យខ្លួនទៅយកម៉ូយចំនួន ២នាក់ជាជនជាតិចិនពីកាស៊ីណូម៉ាការទៅព្រលានយន្ត ហោះភ្នំពេញ នៅពេលទៅដល់ព្រលានយន្តហោះម៉ោង ១១ថ្ងៃត្រង់ ខ្លួនបានដាក់ភ្ញៀវចុះទាំង ពីរនាក់នឹងចូលទៅស៊ីបាយនៅមុខព្រលានយន្តហោះ។ ជាមួយគ្នាខ្លួនបើកឡានមកចាប់ម៉ូយនៅបេនអូឡាំពិចនៅវេលាម៉ោងប្រហែល១រសៀល ពេលខ្លួនចេញឡានមកដល់ផ្សារប្រសូតិជាមួយម៉ូយចំនួន ៣នាក់ ដែលម៉ូយទាំងអស់នេះចុះនៅផ្សារប្រសូតិទាំងអស់ក្នុងអំឡុងម៉ោង ៤រសៀល ។ បន្ទាប់ពីម៉ូយចុះពីឡានខ្លួនអស់ខ្លួនទទួលដឹកគុអ៊ីណុកចំនួន១ និងកៅអីជ័រចំនួន ១០ របស់ឈ្មោះ គុលា នៅផ្សារប្រសូតិ យកទៅឲ្យពូឈ្មោះ វ៉ាន នៅភូមិព្រៃតាញ៉យ ខ្លួនមក ដល់ភូមិព្រៃតាញ៉យនៅម៉ោងប្រហែល ៥និង ៣០នាទីល្ងាច ដាក់គុ នឹងកៅអីជ័រនៅផ្ទះពូវ៉ាន ខ្លួនក៏បើកឡានចូលផ្ទះលាងឡាន ដោយពុំបានចេញទៅណាទៀតនោះទេ ។ ខ្លួនសុំបដិសេធ លើសំដីរបស់ឈ្មោះ [redacted] សុជាតិ ដែលបានឆ្លើយដាក់ខ្លួនថា: ខ្លួនបានទៅចូលរួមរំលោភសម្លាប់ជនរងគ្រោះកាលពីថ្ងៃទី ០២-០៨-២០១៧ ថារឿងនេះពុំពិតទេ ។ ជាមួយគ្នានេះខ្លួនក៏ ពុំដែលមានទំនាក់ទំនងឬក៏មានប្រព័ន្ធទូរស័ព្ទជាមួយឈ្មោះ [redacted] សុជាតិ ម្តងណាដែរ ។

តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីឡូត បានឆ្លើយបញ្ជាក់ថា : កាលពីថ្ងៃទី ២៨-០៧-២០១៧ វេលាម៉ោង៩ព្រឹកខ្លួនបានទូរស័ព្ទទៅកូនឈ្មោះ សុវណ្ណ សុម៉ាលីន ធ្វើការនៅកាស៊ីណូនៅក្រុងបាវិត ដើម្បីឲ្យឡើងមកផ្ទះនៅខេត្តព្រះវិហារ ចូលរួមខួបកំណើតឲ្យប្អូនកូនខ្លួនក៏ឡើងមកខេត្តព្រះវិហារ នឹងបានស់រាកនៅទីនោះបាន៥ថ្ងៃ នឹងនៅថ្ងៃទី ០២-០៨-២០១៧ កូនខ្លួនក៏បានត្រឡប់ទៅធ្វើការនៅក្រុងបាវិតវិញ នៅម៉ោង ១២ថ្ងៃត្រង់ខ្លួនតេសួរកូនស្រីថាទៅដល់ណាហើយ កូនខ្លួនប្រាប់ថា មកដល់ភ្នំពេញហើយកំពុងជិះម៉ូតូកង់បី ទៅរកឡាននៅច្បារអំពៅ មួយម៉ោងក្រោយមកខ្លួនបានតេសួរកូនថាទៅដល់ណាហើយ កូន ស្រីខ្លួនប្រាប់ថាមកដល់កៀនស្វាយហើយ នឹងហូតដល់ម៉ោង ៥ល្ងាចខ្លួនបានតេទៅកូនស្រី ម្តងទៀត កូនស្រីខ្លួនប្រាប់ថា មកដល់ស្វាយរៀងហើយ ដល់ត្រង់ចំណុចផ្សារជីភូ ហើយឡាន គាត់ស៊ីកំពុងទៅយកម៉ូយម្នាក់ទៀតចូលទៅតាមផ្លូវលំ កូនខ្លួនប្រាប់ថា វាមិនស្គាល់ផ្លូវនឹងទេ។លុះដល់ម៉ោង ៦ល្ងាចខ្លួនតេទៅកូនស្រីខ្លួនម្តងទៀតចូលតែគ្មានអ្នកលើក នឹងបន្តតេមក កូនហូតតែទូរស័ព្ទទាក់ទងគ្នាលេងបាន ដោយបារម្ភណ៏ពីកូនខ្លួនក៏ឡើងមកស្វាយរៀង តាមសួររកកូនតែរកមិនឃើញ ហូតដល់ថ្ងៃទី ០៥-០៨-២០១៧ ខ្លួនក៏បានដាក់ពាក្យប្តឹងទៅសមត្ថ កិច្ចឲ្យជួយស្រាវជ្រាវទើបឃើញសាកសពសមត្ថកិច្ចក៏ប្រគល់សាកសពឲ្យខ្លួនយកទៅធ្វើបុណ្យតាមប្រពៃណីតែម្តង នៅក្នុងរឿងហេតុនេះខ្លួនតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ និងសុំទាមទារប្រាក់សំណងចំនួន ៦០ ០០០(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ។

Scanned with CamScanner

តាមចម្លើយសាក្សីប់ត្តីឈ្មោះ [redacted] សុថា បានឆ្លើយបញ្ជាក់ថាៈ កាលពីថ្ងៃទី ០២-០៨-២០១៧ ខ្លួនដឹងតាមបណ្តាញសង្គមថា មានបាត់នារីជំទង់ម្នាក់ចេញដំណើរពីខេត្តព្រះវិហារមកស្វាយរៀង នឹងធ្វើការនៅបាវិត ខ្លួនបានទាក់ទងទៅអធិការនគរបាលក្រុងបាវិតឲ្យ គាត់ជួយទាក់ទងរក ។ ដល់ថ្ងៃទី ០៤-០៨-២០១៧ វេលាប្រហែលម៉ោង ១រសៀលជាង ខ្លួនដឹង ពត៌មានថា ឃើញសាកសពក្មេងស្រីនៅក្នុងស្រែ នៅភូមិតាពៅ សង្កាត់បាវិត ខ្លួនបាននាំក្រុម គ្រួសារអ្នកប្តឹងឲ្យទៅមើលសាកសព នឹងបានចង្អុលបង្ហាញថាជាកូនស្រីរបស់ខ្លួន ។ ជុំវិញការ ឃើញសាកសពខ្លួនទទួលបានពត៌មានថា មានអ្នកឃើញរថយន្តពត៌សខ្ចស់ចតក្បែរកន្លែងសាកសពកាលពីល្ងាចថ្ងៃទី ០២-០៨-២០១៧ ។ នៅថ្ងៃទី ០៦-០៨-២០១៧ សមត្ថកិច្ចយើង បានធ្វើការស្រាវជ្រាវដឹងអ្នកឃើញរថយន្តចតនៅល្ងាចថ្ងៃទី ០២-០៨-២០១៧ នៅក្បែរសាក សពគឺឈ្មោះ [redacted] សាវី និងប្តីឈ្មោះ [redacted] សាមុត ។ នៅពេលដឹងហើយខ្លួនធ្វើការថតរថយន្ត ចំនួន ៣ប្រភេទ គឺ រថយន្តលុចស៊ីស, រថយន្តហាយលេនឌ័ និងរថយន្តសាំងយ៉ុង ទៅបង្ហាញ ឲ្យសាក្សីមើល សាក្សីទាំងពីរនាក់ប្តីប្រពន្ធបញ្ជាក់ថា ឡានហាយលេនឌ័ ខ្លួនក៏បានពិនិត្យផ្លូវ មានតែតាមរោងចក្រយីងមេខ័រ ក៏ឆែកកាមរ៉ាសុវត្ថិភាពរោងចក្រយីងមេខ័រឃើញមានឡានហាយលេនឌ័ពត៌សបើកតាត់នៅវេលាម៉ោង ៦ និង ៤៥នាទីល្ងាច ថ្ងៃទី ០២-០៨-២០១៧ ខ្លួនបាន យកលេខទូរស័ព្ទអ្នករត់កាត់ស៊ីឡានហាយលេនឌ័ចំនួន ១១នាក់ ឆែកឃើញគេហៅចូលលេខទូរស័ព្ទឈ្មោះ [redacted] សុជាតិ នៅវេលាម៉ោង ៦ជាង នៅចំណុចកើតហេតុក្នុងសង្កាត់បាទី។ លុះដល់ថ្ងៃទី ០៨-០៨-២០១៧ សមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ [redacted] សុជាតិ នឹងរថយន្ត របស់ខ្លួនមកសាកសួរនៅការិយាល័យព្រហ្មទណ្ឌ បន្តឆែកឆេរក្នុងរថយន្តរបស់ឈ្មោះ [redacted] សុជាតិ បានឃើញចិញ្ចៀន និងខ្សែកនៅក្នុងឡាន តែឈ្មោះ [redacted] សុជាតិ ប្រកែកខ្លួនបានឲ្យ ម្តាយមីងឈ្មោះ [redacted] ចន្ទ មកចង្អុលបង្ហាញស្គាល់ថាពិតជាខ្សែកនិងចិញ្ចៀនក្មួយស្រីខ្លួន(សព) ច្រកប្រើរាល់ថ្ងៃទើប ឈ្មោះ [redacted] សុជាតិ ឆ្លើយសារភាពថា ខ្លួននឹងឈ្មោះ [redacted] សូនី ជាអ្នក បានប្រព្រឹត្តក្នុងរឿងនេះ ទើបសមត្ថកិច្ចខ្លួនឈានទៅចាប់ឃាត់ខ្លួនឈ្មោះ [redacted] សូនី បញ្ជូនមកគុលាការឃុំខ្លួនរហូតដល់សព្វថ្ងៃ ។

តាមចម្លើយសាក្សីឈ្មោះ [redacted] ចន្ទ បានឆ្លើយបញ្ជាក់ក្នុងពេលសវនាការថា កាលពីថ្ងៃទី ២៨-០៧-២០១៧ ក្មួយស្រីរបស់ខ្លួនឈ្មោះ [redacted] សុម៉ាលីន វាបានទៅលេងផ្ទះនៅខេត្តព្រះវិហារ ប្រាប់រួចក្មួយខ្លួនវាក៏បានចេញទៅ ។ រហូតដល់ថ្ងៃទី ០២-០៨-២០១៨ វេលាម៉ោងប្រហែល៩ព្រឹក ក្មួយស្រីខ្លួនឈ្មោះ [redacted] សុម៉ាលីន វាបានឆាតតាមហ្វេសប៊ុកវាត្រឡប់មកធ្វើការវិញហើយកំពុងជិះឡាន ហើយនៅវេលាម៉ោង ៣រសៀលខ្លួនបានទូរស័ព្ទសួរក្មួយស្រីប្រាប់ថាវាចេញមកដល់អ្នកលឿងហើយ និងនៅម៉ោង ៥ និង៣០នាទីល្ងាច ខ្លួនបានទូរស័ព្ទសួរក្មួយស្រីម្តងទៀតវាប្រាប់ខ្លួនមកដល់ជីភូ តែគេទៅយកម៉ូយនៅផ្លូវលំមួយ និងក្រោយមកខ្លួនបានទូរស័ព្ទសួរក្មួយស្រីម្តងទៀតតែគ្មានអ្នកទទួលរហូតដល់ម៉ោង ៧ យប់ជាងទូរស័ព្ទក្មួយស្រីខ្លួនទាក់ទងលែលបាន ។

តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សាវី បានឆ្លើយបញ្ជាក់ក្នុងពេលសវនាការ

Scanned with CamScanner

ថា: កាលពីថ្ងៃទី ០២-០៨-២០១៧ វេលាម៉ោង ៦និង១០នាទីល្ងាច ខ្លួនជិះម៉ូតូចេញពីផ្ទះមកយកប្តីធ្វើការនៅរោងចក្រស៊ីកូ ពេលខ្លួនមកដល់ត្រង់ចំណុចភូមិឈ្មោះ [redacted] សាក់ន ស្ថិតនៅក្នុងភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ខ្លួនឃើញឡានពណ៌ស១គ្រឿង មិនស្គាល់ម៉ាកឈប់បែរមុខទៅជើង នៅលើចិញ្ចើមថ្នល់ខាងកើតម្តុំសាកសពក្មេងស្រីដែលស្លាប់ត្រូវបានប្រជាពលរដ្ឋប្រទះឃើញនោះ ។ ពេលខ្លួនឃើញនោះគ្មានឃើញមនុស្សនៅក្បែររថយន្តទេ និងពុំបានចាប់អារម្មណ៍ពិនិត្យមើលកិនភាគរថយន្តនោះដែរ ក៏ជិះម៉ូតូទៅយកប្តីតែម្តង ។ នៅវេលាម៉ោង ៦ និង ២៥នាទីល្ងាច ពេលប្តីខ្លួនចេញពីធ្វើការក៏នាំគ្នាជិះម៉ូតូវិលត្រឡប់មកផ្ទះវិញ ហើយក៏បានឃើញរថយន្តនោះនៅកន្លែងដដែល ខ្លួននិងប្តីក៏ជិះម៉ូតូទៅផ្ទះទៅ ។ លុះដល់ថ្ងៃទី ០៤-០៨-២០១៧ វេលាម៉ោង ៣ជាងខ្លួនឮគេនិយាយថាមានសាកសពក្មេងស្រីម្នាក់ស្លាប់នៅម្តុំកន្លែងដែលខ្លួនឃើញឡានឈប់ពីថ្ងៃមុន ។

តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សាមុត បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី ០២-០៨-២០១៧ វេលាម៉ោង ៦និង៣០នាទីល្ងាច ខ្លួនចេញពីធ្វើការនៅរោងចក្រស៊ីកូ ជិះម៉ូតូដឹកប្រពន្ធមកផ្ទះវិញ ពេលខ្លួនជិះមកដល់ត្រង់មុខរបងភូមិឈ្មោះ [redacted] សាក់ន ស្ថិតនៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង ឃើញរថយន្តពណ៌សចំនួន១គ្រឿងឈប់ចតបែរមុខទៅជើងនៅលើចិញ្ចើមផ្លូវខាងកើត តែពុំឃើញមានមនុស្សនៅក្បែរឡាននោះទេ ឡាននៅបញ្ឆេះម៉ាស៊ីន តែគ្មានបើកភ្លើងទេ ហើយខ្លួនក៏ពុំចាប់អារម្មណ៍ថាឡានម៉ាកអី មានស្លាកលេខប៉ុន្មានដែរ ។ លុះនៅថ្ងៃទី ០៤-០៨-២០១៧ វេលាម៉ោង ៥រសៀលប្រពន្ធខ្លួនប្រាប់ខ្លួនថាមានសាកសពគេយកទៅបោះចោលនៅចំណុចឡានឈប់កាលពីថ្ងៃមុន ។

តាមចម្លើយសាក្សីឈ្មោះ [redacted] សុខខេង,ឈ្មោះ [redacted] យ៉ូន,ឈ្មោះ [redacted] ធឿន ជាសាក្សីដោះបន្ទុកឱ្យជនជាប់ចោទឈ្មោះ [redacted] សូនីបានឆ្លើយបញ្ជាក់ប្រហាក់ប្រហែលគ្នាបញ្ជាក់ក្នុងពេលសវនាការថា: ពួកខ្លួនស្គាល់ឈ្មោះ [redacted] សូនី និងឈ្មោះ [redacted] សុជាតិ ច្បាស់ដោយអ្នកទាំងពីររស់នៅស្រុកភូមិជាមួយគ្នា និងមានមុខរបររកស៊ីជួលឡានតាក់ស៊ីដូចគ្នា ក្នុងរយៈពេលកន្លងមកតាមពួកខ្លួនដឹងគឺឈ្មោះ [redacted] សូនី និងឈ្មោះ [redacted] សុជាតិ មិនសូវត្រូវនិងគ្នាទេ ដោយឈ្មោះ [redacted] សុជាតិ ខឹងនិងឈ្មោះ [redacted] សូនី ដណ្តើមម៉ូយដឹកមិនឈ្នះរករឿងវាយឈ្មោះ [redacted] សូនី ។

តាមចម្លើយសាក្សីឈ្មោះ [redacted] សាក់ន,ឈ្មោះ [redacted] ណាត ជាសាក្សីដោះបន្ទុកឱ្យជនជាប់ចោទឈ្មោះ [redacted] សូនី បានឆ្លើយប្រហាក់ប្រហែលគ្នាបញ្ជាក់ក្នុងពេលសវនាការថា: នៅថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៧ វេលាម៉ោងប្រហែល ៥ និង ៣០នាទីល្ងាច ពួកខ្លួនឃើញឈ្មោះ [redacted] សូនី ដឹកគុអីណុក និងកៅអីជ័រ ឱ្យឈ្មោះ [redacted] សារិ ដែលផ្ទះរបស់វាលក់បបរ នៅភូមិព្រៃតាញ៉យ ឃុំ ខ្សែត្រ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដោយពួកខ្លួនមានផ្ទះនៅក្បែរគ្នា នៅពេលដាក់គុនិងកៅអីរួចពួកខ្លួនឃើញ [redacted] សូនី បើកឡានចូលទៅផ្ទះតែម្តងពុំទៅណាទៀតទេ ។

តាមចម្លើយឈ្មោះ [redacted] សារុធ ជាសាក្សីដោះបន្ទុកឱ្យជនជាប់ចោទឈ្មោះ [redacted] សូនី បានឆ្លើយបញ្ជាក់ក្នុងពេលសវនាការថា: កាលពីថ្ងៃទី ០២-០៨-២០១៧ វេលាម៉ោង ៥និង

Scanned with CamScanner

៣០នាទីល្ងាច ខ្លួនកំពុងអង្គុយលេងជាមួយឈ្មោះវ៉ាងម្ចាស់ផ្ទះនៅលើគ្រែមុខផ្ទះឃើញឈ្មោះ [redacted] សូនី បើកឡានដឹកគុអីណុកនិងកៅអីជ័រមកឱ្យឈ្មោះវ៉ាង និងប្រពន្ធឈ្មោះ [redacted] សារិ ចូលដាក់ទុកនៅផ្ទះគាត់រួច [redacted] សូនី បើកឡានចូលទុកផ្ទះតែម្តងពុំឃើញបើកចេញទៅណាទេ ។

តាមចម្លើយឈ្មោះ [redacted] វ៉ាង និងឈ្មោះ [redacted] សារិ សាក្សីដោះបន្ទុកឱ្យជនជាប់ចោទឈ្មោះ [redacted] សូនី បានឆ្លើយប្រហាក់ប្រហែលគ្នាថាៈ កាលពីថ្ងៃទី ០២-០៨-២០១៧ វេលាម៉ោង៤ និង ៣០នាទីល្ងាច ប្រពន្ធខ្លួនបានខ្ចីទូរស័ព្ទក្មួយឈ្មោះ យឹម គេទៅទិញគុអីណុក១និងកៅអីជ័រចំនួន ១០ពីឈ្មោះ [redacted] គុលា នៅផ្សារប្រសូតិ និងបានតេតាមទូរស័ព្ទឱ្យក្មួយឈ្មោះ [redacted] សូនី ចូលដឹកយកមកឱ្យ ។ លុះដល់ម៉ោងប្រហែល ៥និង៣០នាទីល្ងាច ពេលខ្លួនកំពុងនៅផ្ទះឃើញឈ្មោះ [redacted] សូនី ដឹកគុនិងកៅអីមកដល់មុខផ្ទះខ្លួន និងបានហុចវិក័យប័ត្រទូទាត់ប្រាក់ផងជាមួយគ្នានោះខ្លួនឱ្យថ្លៃដឹកចំនួន ១០ ០០០រៀល តែក្មួយខ្លួនឈ្មោះ [redacted] សូនី មិនយកទេ និងឃើញបើកឡានចេញពីផ្ទះខ្លួនទៅចូលផ្ទះវាក្បែរនោះទៅ ។

តាមចម្លើយឈ្មោះ [redacted] គុលា និងឈ្មោះ [redacted] ស៊ីភួន ជាសាក្សីដោះបន្ទុកឱ្យជនជាប់ចោទឈ្មោះ [redacted] សូនី បានឆ្លើយបញ្ជាក់ប្រហាក់ប្រហែលគ្នាក្នុងពេលសវនាការថាៈ កាលពីថ្ងៃទី ០២-០៨-២០១៧ វេលាម៉ោង ៤ និង ៤០នាទីល្ងាចមីងឈ្មោះ [redacted] សារិ នៅភូមិព្រៃតាញ៉យ ឃុំខ្សែត្រ បានទូរស័ព្ទមកខ្លួនទិញគុអីណុក១និងកៅអីជ័រចំនួន១០ និងបានប្រាប់ខ្លួនទៀតថាឱ្យពូឈ្មោះ [redacted] សូនី ដឹកទៅឱ្យគាត់ បន្តិចក្រោយមកពូ សូនី បានបើកឡានមកដល់ផ្ទះខ្លួនហើយពូ [redacted] សូនី បើកគូថឡានឱ្យប្ដីប្រពន្ធខ្លួនដាក់គុនិងកៅអី ឯពូ [redacted] សូនី ចូលផ្សារទិញម្ហូប មកវិញខ្លួនហុចវិក័យប័ត្រគុនិងកៅអីឱ្យទៅគាត់និងបើកឡានចេញទៅបាត់ទៅ ។

តាមចម្លើយឈ្មោះ [redacted] វណ្ណា ភេទ ស្រី( ជាប្រពន្ធឈ្មោះ [redacted] សុជាតិ) បានឆ្លើយបញ្ជាក់ក្នុងពេលសវនាការថាៈ កាលពីថ្ងៃទី ០៤-០៨-២០១៧ នៅផ្ទះរបស់ខ្លួនមានកម្មវិធីសូត្រមន្ត មានហៅបងប្អូនចូលរួម ក្រោយកិច្ចសូត្រមន្តចប់ក៏មានកម្មវិធីហូបចុកធម្មតាជាមួយបងប្អូនហើយក្នុងពេលនោះខ្លួនឃើញប្ដីខ្លួន [redacted] សុជាតិ បក់ដៃហៅឈ្មោះ [redacted] សូនី ចូលរួមផឹកស៊ីនៅផ្ទះខ្លួនក្នុងពេលនោះដែរ ដោយមិនដែលមានទំនាស់អ្វីនិងគ្នាទេ ។

តាមចម្លើយឈ្មោះ [redacted] ជីវន្ត ភេទ ប្រុស អាយុ ២១ឆ្នាំ និងឈ្មោះ [redacted] វង ភេទ ប្រុស អាយុ ៣១ឆ្នាំ បានឆ្លើយបញ្ជាក់ក្នុងពេលសវនាការថាៈ កាលពីថ្ងៃទី ០៤-០៨-២០១៧ ពួកខ្លួនត្រូវជាបងប្អូននិងគ្នាបានមកចូលរួមក្នុងកម្មវិធីសូត្រមន្តនៅផ្ទះបង [redacted] សុជាតិ នៅភូមិព្រៃតាញ៉យ ឃុំខ្សែត្រ ស្រុកកំពង់ពេទិ៍ ចប់សូត្រមន្តមានកម្មវិធីហូបចុះ ពួកខ្លួនបានឃើញឈ្មោះ [redacted] សូនី ឈប់ឡាន នៅជិតនោះនិងឃើញបង [redacted] សុជាតិ បក់ដៃហៅឈ្មោះ [redacted] សូនី មកចូលរួមក្នុងកម្មវិធីផ្ទះរបស់គាត់ ឈ្មោះ [redacted] សូនី ដើរចូលមកធម្មតា ពុំមានឈ្មោះ [redacted] សុជាតិ ដើរទៅកៀកកទាញមកចូលក្នុងផ្ទះគាត់នោះទេ ពេលមកដល់ឈ្មោះ [redacted] សូនី ហូបចុកធម្មតា និងបានឱ្យប្រាក់ពួកខ្លួនចំនួន ១៥ ០០០រៀល ជួយទិញស្រាបៀរមកផឹកបន្តទៀតពួកខ្លួនថែមលុយទិញបានស្រាបៀរចំនួន ១កេះ មកផឹកថែមទៀតផង ។

Scanned with CamScanner

តាមចម្លើយឈ្មោះ [redacted] ស្រីលក្ខ័ណា ភេទ ស្រី អាយុ ២៧ឆ្នាំ បានឆ្លើយបញ្ជាក់ ក្នុងពេលសវនាការថា: កាលពីថ្ងៃទី ០៥-០៨-២០១៧ នៅផ្ទះបងស្រីខ្លួនមានកម្មវិធីសូត្រមន្ត នៅពេលចប់កម្មវិធីសូត្រមន្តក៏មានកម្មវិធីហូបចុះដោយខ្លួនជាអ្នកជួយធ្វើម្ហូបនិងទទួលភ្ញៀវនៅទីនោះដែរ ខ្លួនបានឃើញឈ្មោះ [redacted] សូនី ឈប់ឡាននៅក្បែរនោះ ហើយឃើញឈ្មោះ [redacted] សុជាតិ បក់ដៃហៅឈ្មោះ [redacted] សូនី ក៏ដើរចូលមករួមកម្មវិធីជាមួយគេឯងធម្មតា ដោយពុំមានឈ្មោះ [redacted] សុជាតិ ទៅចាប់កៀកកនាំមកចូលក្នុងផ្ទះគាត់កំពុងមានកម្មវិធីនោះទេ ។

តាមអំណានចម្លើយឈ្មោះ [redacted] សេក បានឆ្លើយបញ្ជាក់ថា: ឈ្មោះ [redacted] សូនី និងប្រពន្ធឈ្មោះ [redacted] សូន្យ ពួកគេត្រូវជាក្មួយរបស់ខ្លួន ។ នៅក្នុងខែ សីហា ឆ្នាំ ២០១៧ ក្មួយខ្លួនឈ្មោះ [redacted] សូនី ចង់បានឡានខ្ពស់ស្រួលដឹកម៉្យ ពួកគេទាំងពីរនាក់ប្តីប្រពន្ធបានមកពឹងខ្លួនឱ្យជួយខ្ចីប្រាក់ពីធនាគារចំនួន ២០ ០០០ដុល្លារអាមេរិក ទិញឡានខ្ពស់ជារបស់វា នៅថ្ងៃទី ១៩-០៥-២០១៧ ខ្លួនយកប្លង់ដីខ្លួនទៅដាក់ខ្ចីប្រាក់ពីធនាគារហត្ថាកសិករលើមីតធីតខ្ចីបានប្រាក់ចំនួន ២០ ០០០ដុល្លារអាមេរិកហើយនៅថ្ងៃទី ២០-០៥-២០១៧ ខ្លួនបានទៅទិញឡានជាមួយក្មួយនៅភូមិបាក់នាស់ សង្កាត់សង្ឃ័រ ក្រុងស្វាយរៀង ក្នុងតម្លៃ ១០ ៩០០ដុល្លារអាមេរិក ប្រាក់នៅសល់ខ្លួនឱ្យក្មួយទាំងពីរ តែមុនទៅខ្ចីប្រាក់ខ្លួនបានធ្វើកិច្ចសន្យាជាមួយក្មួយថ្លៃ [redacted] សូន្យ នៅថ្ងៃទី ១៨-០៥-២០១៧ ដោយក្មួយប្រុសខ្លួនទៅរត់គាក់ស៊ី និងខ្លាចក្មួយស្រីខ្លួនក្រឡាស់សុំដីទៅថ្ងៃក្រោយ ឡានដែលក្មួយខ្លួនទិញនោះគឺ លុចស៊ីស ៣០០ ក្មួយខ្លួនរត់គាក់ស៊ីបង់ឱ្យទៅធនាគារវិញបានចំនួន ៣ខែមកហើយ ។ ដូច្នេះឡានលុចស៊ីស ៣០០ ដែលសមត្ថកិច្ចដកហូតពីឈ្មោះ [redacted] សូនី(ក្មួយខ្លួន)គឺជារថយន្តដែលខ្លួនខ្ចីប្រាក់ពីធនាគារឱ្យក្មួយទិញពិតមែន ។

តាមអំណានចម្លើយឈ្មោះ [redacted] សូន បានឆ្លើយបញ្ជាក់ថា: ខ្លួននិងប្តីពុំមានប្លង់ដីតម្លៃ ២០ ០០០ដុល្លារអាមេរិក ទៅខ្ចីប្រាក់ពីធនាគារទេ ពឹងមីង ឃ្លាំង សេក យកប្លង់ដីគាត់ និងឈ្មោះ គាត់ទៅខ្ចីប្រាក់ពីធនាគារហត្ថាកសិករបានប្រាក់ ២០ ០០០ដុល្លារអាមេរិក យកទៅទិញឡាន លុចស៊ីស ៣០០អស់តម្លៃ ១០ ៩០០ដុល្លារអាមេរិក ។ តែមុនខ្ចីប្រាក់មីងខ្លួនបានឱ្យខ្លួនធ្វើកិច្ចសន្យា ចុះថ្ងៃទី ១៨-០៥-២០១៧ដល់ថ្ងៃទី ១៩-០៥-២០១៧ មីងទៅបើកប្រាក់ និងនៅថ្ងៃទី ២០-០៥-២០១៧ ទៅទិញឡាន ប្រាក់នៅសល់ពីទិញឡានមីងខ្លួនប្រគល់ឱ្យខ្លួនទាំងអស់ទុកធ្វើដើមរកស៊ី ប្តីខ្លួនរត់គាក់ស៊ីបង់ប្រាក់សងទៅឱ្យធនាគារបានចំនួន ៣ខែមកហើយ ។

តំណាងអយ្យការនាពេលសវនាការបានធ្វើសេចក្តីសន្និដ្ឋានថា: ទ្បិតតែនៅក្នុងពេលសវនាការនេះឈ្មោះ [redacted] សុជាតិ បានឆ្លើយសារភាពនូវកំហុសរបស់ខ្លួនចំពោះមុខអង្គសវនាការក្នុងពេលនេះ តែឈ្មោះ [redacted] សូនី បានឆ្លើយបដិសេធថាខ្លួនពុំបានដឹង និងចូលរួមក្នុងអំពើឃាតកម្មនេះក៏ដោយ និងថាឈ្មោះ [redacted] សុជាតិ បានឆ្លើយទំលាក់កំហុសមកឱ្យខ្លួនក៏ដោយ តំណាងអយ្យការនៅតែរក្សាការចោទប្រកាន់លើឈ្មោះ [redacted] សុជាតិ និងឈ្មោះ [redacted] សូនី ពីបទ:ឃាតកម្មដោយមានទារុណកម្ម អំពើរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី ០២-០៨-២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌនិងសុំតម្កល់ដីកាសន្និដ្ឋាន

Scanned with CamScanner

ស្តាពរលេខ ២៥៥ អយ ចុះថ្ងៃទី ២៣-១១-២០១៧ របស់តំណាងអយ្យការអមសាលាដំបូង ខេត្តស្វាយរៀង ទុកជាបានការដដែល និងស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជំរះសម្រេចផ្តន្ទាទោសជន ទាំងពីរនាក់ឱ្យបានតឹងរឹងបំផុតតាមច្បាប់ ។

មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានការពារឱ្យកូនក្តីលោកស្រីក្នុងពេលសវនាការថា: ត្បិតតែឈ្មោះ [redacted] សុជាតិ បានសារភាពនូវទោសកំហុសរបស់ខ្លួនចំពោះមុខអង្គសវនាការក្នុងពេលនេះ តែសំរាប់ជនជាប់ចោទឈ្មោះ [redacted] សុទី បានបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដោយថា [redacted] សុជាតិ ឆ្លើយទំលាក់កំហុសមកលើខ្លួន និងក៏មានសាក្សីដោះបន្ទុកច្រើននាក់សុទ្ធតែជាបងប្អូនសាច់ញាតិ តែក្នុងពេលនេះ ខ្លួនក៏មានសាក្សីដាក់បន្ទុកទៅលើជនជាប់ចោទឈ្មោះ [redacted] សុទី ដែរ ដោយជនជាប់ចោទរូបនេះថា ខ្លួននិង [redacted] សុជាតិ មុនពេលមានរឿងហេតុធ្លាប់មានទំនាស់គ្នា មិនដែលរាប់គ្នាទេ និងថាមិនដែលទាំងមានលេខទូរស័ព្ទជាមួយគ្នាផង ។ ជាក់ស្តែងសាក្សីឈ្មោះ [redacted]ណ្ណា(ប្រពន្[redacted] សុជាតិ)ឈ្មោ[redacted] ជីវ័ន្ត ភេទ ប្រុស,ឈ្មោះ [redacted] វង ភេទ ប្រុស និងឈ្មោះ [redacted] ស្រីលក្ខ័ណ ភេទ ស្រី បានឆ្លើយបញ្ជាក់ប្រហាក់ប្រហែលគ្នាថា: ឈ្មោះ [redacted] សុជាតិ និងឈ្មោះ [redacted] សុទី មិនដែលមានទំនាស់ឈ្លោះប្រកែកគ្នាមានពីមុនមកនោះទេ ជាក់ស្តែងនៅថ្ងៃទី ០៤-០៨-២០១៧ ក្នុងពេលសូត្រមន្តនៅផ្ទះឈ្មោះ [redacted] សុជាតិ គឺឈ្មោះ [redacted] សុទី មកឈប់ឡានចូលផឹកស៊ីធម្មតានៅផ្ទះឈ្មោះ [redacted] សុជាតិ ។ ដូច្នេះចម្លើយបដិសេធរបស់ឈ្មោះ [redacted] សុទី ក៏ដូចជាចម្លើយសាក្សីដោះបន្ទុកឱ្យជនជាប់ចោទ [redacted] សុទី គ្រាន់តែជាចម្លើយដោះសារនិងដោះបន្ទុកតែប៉ុណ្ណោះពុំមានហេតុផលណាឱ្យក្រុមប្រឹក្សាជឿបានទេ ខ្លួនជាមេធាវីឱ្យដើមបណ្តឹង នៅតែសុំឱ្យក្រុមប្រឹក្សាជំនុំជំរះសំរេចផ្តន្ទាទោសជនជាប់ចោទទាំងពីរនាក់ឱ្យបានតឹងរឹងតាមច្បាប់ ។

មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] សុជាតិ បានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីលោកថា: កូនក្តីលោកគឺឈ្មោះ [redacted] សុជាតិ បានឆ្លើយសារភាពនូវទោសកំហុសទាំងអស់របស់ខ្លួនចំពោះមុខក្រុមប្រឹក្សាជំនុំជំរះអស់រួចហើយ និងសន្យាកែប្រែខ្លួនឱ្យទៅជាពលរដ្ឋល្អទៅថ្ងៃអនាគត ។ តែដោយឡែកជនជាប់ចោទឈ្មោះ [redacted] សុទី ដែលកូនក្តីខ្លួនបញ្ជាក់ថាជាអ្នកចូលដៃចូលជើងជាមួយគ្នាដែរបែរជាខំប្រកែកបដិសេធថា មិនបានរួមប្រព្រឹត្ត ខ្លួនសូមបញ្ជាក់ថា មនុស្សដែលកូនក្តីខ្លួនស្គាល់មានច្រើនណាស់មិនតែឈ្មោះ [redacted] សុទី ម្នាក់នេះទេ ចុះហេតុអ្វីបានជាកូនក្តីខ្លួន [redacted] សុជាតិ) និយាយប្រាប់ក្រុមប្រឹក្សាជំនុំជំរះក្នុងពេលនេះសំដៅតែឈ្មោះ [redacted] សុទី តែម្នាក់អញ្ចឹងថាបានចូលរួមប្រព្រឹត្តជាមួយខ្លួន ម៉េចក៏មិននិយាយមនុស្សគគោកដែលកូនក្តីខ្លួនស្គាល់ថាបាន ទៅចូលរួមរំលោភសម្លាប់ជាមួយខ្លួនផងដែរទៅ កាលពីថ្ងៃទី ០២-០៨-២០១៧នោះ ។ ខ្លួនជាមេធាវីស្នើសុំក្រុមប្រឹក្សាជំនុំជំរះជួយបន្ធូរបន្ថយនិងអនុគ្រោះដល់កូនក្តីខ្លួន [redacted] សុជាតិ ដោយផ្អែកតាមមាត្រា ៩៣-៩៤ នៃក្រមព្រហ្មទណ្ឌ ។

មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] សុទី បានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តី លោកថា: ត្បិតចម្លើយកូនក្តីលោកនៅចំពោះមុខសមត្ថកិច្ចមានភាពផ្ទុយគ្នានៅចំពោះមុខចៅក្រមស៊ើបសួរ តែចំណុចដែលខ្លួនបានកត់សំគាល់នោះនៅត្រង់ថា កូនក្តីខ្លួនបានសុំឱ្យសមត្ថ

Scanned with CamScanner

កិច្ចក៏ដូចចៅក្រមស៊ើបសួរជួយរកយុត្តិធម៌ឱ្យខ្លួនផងដោយថាខ្លួនពុំបានប្រព្រឹត្ត ចំណុចនេះមិនត្រូវបានសមត្ថកិច្ចនិងតំណាងអយ្យការយកមកពិចារណាទេ ។ ម្យ៉ាងទៀតចម្លើយសាក្សីដោះបន្ទុកឱ្យកូនក្តីខ្លួនទាំងអស់សុទ្ធតែបានឃើញ ដឹង ឮ ថានៅថ្ងៃកើតហេតុគឺថ្ងៃទី ០២-០៨-២០១៧ កូនក្តីខ្លួនឈ្មោះ [redacted] សូនី នៅវេលាម៉ោង ៤ ជាងកំពុងដាក់គុនិងកៅអីនៅផ្សារប្រសូតិនិងចូលផ្សារទិញម្ហូប និងបើកឡានដឹកគុនិងកៅអីចំនួន១០ទៅឱ្យឈ្មោះ វ៉ាង និងឈ្មោះ [redacted] សារិ នៅភូមិព្រៃញ៉យ ឃុំខ្សែត្រ ស្រុកកំពង់រោទិ៍ ទៅដល់ទីនោះម៉ោង ៥និង៣០នាទីល្ងាច នៅពេលដាក់គុ និងកៅអីទុកនៅផ្ទះឈ្មោះ [redacted] និង [redacted] សារិ ហើយបានបើកឡានខ្លួនចូលទុកនៅផ្ទះតែម្តងដោយពុំបានឃើញកូនក្តីខ្លួនបើកឡានចេញទៅណាទៀតទេ ។ ចំណុចនេះវាស៊ីសង្វាក់ទៅនិងចម្លើយរបស់កូនក្តីខ្លួនដែលថា នៅវេលាម៉ោង ៤ជាងខ្លួនចេញពីភ្នំពេញដឹកម៉ូយចំនួន៣នាក់មកចុះនៅផ្សារប្រសូតិទាំងអស់និងទុកឡាននៅផ្ទះឈ្មោះគុលា និងប្រពន្ធឈ្មោះ ស៊ីភូន បើកគូថឡានឱ្យគេដាក់គុនិងកៅអី១០ ខ្លួនចូលផ្សារប្រសូតិទិញម្ហូប មកវិញដឹកគុនិងកៅអីទៅឱ្យឈ្មោះ វ៉ាង និងប្រពន្ធឈ្មោះ [redacted] សារិ មានផ្ទះនៅក្បែរផ្ទះខ្លួនដែរ នៅវេលាម៉ោង៥និង៣០នាទីល្ងាចដាក់គុកៅអីរួចកូនក្តីខ្លួនយកឡានចូលផ្ទះដោយពុំទៅណាទៀតទេ ។ ដូច្នេះនៅមុខអង្គសវនាការនេះខ្លួនជាមេធាវីការពារឱ្យឈ្មោះ [redacted] សូនី ស្នើសុំក្រុមប្រឹក្សាជំនុំជំរះពិនិត្យពិចារណា បើគ្រាន់តែមានតែសំដីឈ្មោះ [redacted] សុជាតិ ម្នាក់ឆ្លើយដាក់ទំលាក់កំហុសមកលើកូនក្តីលោក មិនអាចយកជាការបានទាំងស្រុងបាននោះទេ ខ្លួនស្នើឱ្យក្រុមប្រឹក្សាជំនុំជំរះសម្រេចឱ្យកូនក្តីខ្លួនបានរួចពីបទចោទប្រកាន់ និងដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាពវិញ ។

ជនជាប់ចោទឈ្មោះ [redacted] សុជាតិ បានសំណូមពរជាសំដីចុងក្រោយបង្អស់ថា ខ្លួន ពិតជាបានប្រព្រឹត្តខុសហើយ សុំឱ្យក្រុមប្រឹក្សាជំនុំជំរះជួយបន្ធូរបន្ថយឬអនុគ្រោះទោសដល់ខ្លួន ផងដោយឡែកជនជាប់ចោទឈ្មោះ [redacted] សូនី បានសំណូមពរជាសំដីចុងក្រោយបង្អស់ថា ខ្លួន ពុំបានប្រព្រឹត្តខុសនោះទេ សុំឱ្យក្រុមប្រឹក្សាជំនុំជំរះជួយរកយុត្តិធម៌និងដោះលែងខ្លួនផង ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
ក្រោយពីបានស្តាប់ចម្លើយសាក្សី
ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី
ក្រោយពីបានស្តាប់ពិនិត្យលើភស្តុតាងនានា
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពារមេធាវីឱ្យដើមបណ្តឹង
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពារមេធាវីជនជាប់ចោទ
ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងខេត្តស្វាយរៀង**

<u>យល់ឃើញថា</u>: តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និង ការស្វែងរកដោយចៅក្រមស៊ើបសួរពុំឃើញមានភាពផ្ទុយគ្នាទេ ។ យោងតាមមាត្រា ១១០ និងតាមមាត្រា

Scanned with CamScanner

១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អាចឲ្យតុលាការជឿបានថា: កាលពីថ្ងៃទី ០២-០៨-២០១៧ វេលាម៉ោងប្រហែល ៦និង ៣០ល្ងាច ស្ថិតនៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង មានបទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ រំលោភសេពសន្ថវៈមួយកើតឡើង ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] សុជាតិ និងឈ្មោះ [redacted] សូនី ទៅលើជនរងគ្រោះឈ្មោះ [redacted]ុម៉ាលីន ពិតប្រាកដមែន ។

<u>យល់ឃើញថា</u>:ជនជាប់ចោទឈ្មោះ [redacted] សុជាតិថា:កាលពីថ្ងៃទី ០២-០៨-២០១៧ វេលាម៉ោងប្រហែល២រសៀលជនជាប់ចោទដឹកម៉ូយប្រុសៗចំនួន៥នាក់និងស្រីម្នាក់ ចេញពីភ្នំពេញឆ្ពោះមកបាវិត ។ ពេលមកដល់ក្បាលស្ពានអ្នកលឿងត្រើយខាងលិចជនជាប់ចោទបានដាក់ម៉ូយប្រុសៗចំនួន២នាក់ចុះ និងបានជួបឈ្មោះ [redacted] សូនី ដឹកម៉ូញមកដល់តាមក្រោយដែរ ដោយបើកឡានយឺតៗ ពេលនោះជនជាប់ចោទបានប្រាប់ឈ្មោះ [redacted] សូនី ថាមានស្រី ស្អាត ឯឈ្មោះ [redacted] សូនី ថាយកទៅ រួចក៏បើកឡានបង្ហួសទៅមុនបាត់ទៅ ។ នៅពេលជនជាប់ចោទមកដល់ផ្សារកេអណ្តើកបានដាក់ម៉ូយប្រុសៗចំនួន២នាក់ទៀតចុះរួចបើកឡានមកដល់ស្វាយរៀង ហើយឈ្មោះ [redacted] សូនី ទូរស័ព្ទមកលេខ ០៩៧ ៨០៦១១០៨ ប្រាប់ជនជាប់ចោទថា: វាទៅចាំនៅមុខពេទ្យជីភូ នៅពេលមកដល់មុខពេទ្យជីភូជនជាប់ចោទបានដាក់ម៉ូយប្រុសម្នាក់ទៀតចុះ នៅសល់តែនារីម្នាក់ដែលទៅបាវិត ឈ្មោះ [redacted] សូនី បានឡើងជិះឡានជនជាប់ចោទបាំងក្រោយនិងប្រាប់ថា ទៅយកពួកម៉ាកវានៅសាលាស្រុកចន្ទ្រា ពេលបើកឡានទៅដល់សាលាស្រុកចន្ទ្រា(ផ្លូវកែងមេសថ្ងក) [redacted] សូនី ប្រាប់ថា ពួកម៉ាកវាមិននៅទេ ជនជាប់ចោទបើកឡានដឹកស្ត្រីជនរងគ្រោះទៅបាវិត នៅពេលនោះ [redacted] សូនី ចាប់ផ្តើមចាប់ស្ត្រី រងគ្រោះរំលោភនៅក្នុងឡានរបស់ជនជាប់ចោទ ហូតទៅដល់ត្រង់ចំណុចភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ជនជាប់ចោទបានឈប់ឡាន ចុះទៅឃើញជនរងគ្រោះដេកសន្លប់នៅក្នុងឡាន ជនជាប់ចោទទៅរំលោភម្តង ពេលរំលោភហើយ ឈ្មោះ [redacted] សូនី ក៏យកកន្សែងរឹតកជនរងគ្រោះរហូតដល់ស្លាប់ ជនជាប់ចោទបានឃាត់ [redacted] សូនី ថាកុំសម្លាប់គេតែ [redacted] សូនី មិនស្តាប់និងនិយាយថា ទុកនាំមានរឿង ហើយ [redacted] សូនី ចាប់អូសសាកសពជនរងគ្រោះយកទៅបោះចោលក្នុងស្រែក្បែរនោះ ដោយយកដុំថ្ម ដាក់សង្កត់ពីលើផង និងខ្លួនបើកឡានចេញមកតាមផ្លូវតាព្រហ្មមកជីភូវិញតែម្តង ។ការសារភាព របស់ជនជាប់ចោទខាងលើ តុលាការលើកយកមកពិនិត្យពិចារណាសម្រេចតាមច្បាប់ ។

<u>យល់ឃើញថា</u>: ជនជាប់ចោទឈ្មោះ [redacted] សូនី បានឆ្លើយបដិសេធថា: កាលពីថ្ងៃទី ០២-០៨-២០១៧ ពេលព្រឹកជនជាប់ចោទទៅដឹកម៉ូយពីកាស៊ីណូនៅក្រុងបាវិតឆ្ពោះទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញចំនួន២នាក់ នៅពេលដាក់ភ្ញៀវចុះហើយនៅវេលាម៉ោង ១១ថ្ងៃត្រង់ជនជាប់ចោទបានស៊ីបាយនៅមុខព្រលានយន្តហោះ ។ នៅវេលាម៉ោងប្រហែល ១រសៀលជនជាប់ចោទមកចាប់ម៉ូយនៅបេនអូរឡាំពិកបានម៉ូយ៣នាក់ ពេលមកដល់ផ្សារប្រសូតិនៅវេលាម៉ោងប្រហែល ៥រសៀល ជនជាប់ចោទដាក់ម៉ូយចុះទាំអស់នៅផ្សារប្រសូតិ និងបានយកឡានទៅដាក់តុនិងកៅអីជ័រចំនួន១០នៅផ្ទះឈ្មោះ តុលា និងប្រពន្ធឈ្មោះ ភួន រួចចូលទៅក្នុងផ្សារទិញម្ហូប មកវិញដឹកតុនិង កៅអីយកទៅឱ្យមីង [redacted] សាវិន និងប្តីឈ្មោះ រ៉ាន ដែលនៅស្រុកភូមិជាមួយគ្នា(ភូមិព្រៃតាញ៉យ ឃុំ ខ្សែត្រ ស្រុកកំពង់រោទិ៍)នៅវេលាម៉ោងប្រហែល ៥និង៣០នាទីល្ងាច ពេលដាក់តុនិងកៅអីហើយ ជនជាប់ចោទបើកឡានចូលផ្ទះលាងដោយពុំបានចេញទៅណាទៀតទេ និងសុំបដិសេធសំដីរបស់ឈ្មោះ [redacted] សុជាតិ ដែលថា ជនជាប់ចោទរួមរំលោភសម្លាប់ស្ត្រីរងគ្រោះកាលពីថ្ងៃទី ០២-០៨-២០១៧ ថាមិន ពិតទេ និងថាជនជាប់ចោទនិង [redacted] សុជាតិ មានទំនាស់គ្នាយូរហើយមិនដែលមានទំនាក់ទំនងគ្នាទេ ។ ប៉ុន្តែបើតាមចម្លើយជនជាប់ចោទនៅចំពោះមុខសមត្ថកិច្ចក្នុងកំណត់ហេតុចុះថ្ងៃទី ០៨-០៨-២០១៧ ជនជាប់ចោទ [redacted] សូនី អះអាងថា: នៅថ្ងៃទី ០២-០៨-២០១៧ ពេលព្រឹកជនជាប់ចោទដឹកភ្ញៀវ ចំនួន ២នាក់ពីកាស៊ីណូក្រុងបាវិត ទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ។ នៅវេលាម៉ោងប្រ ហែល ១និង៣០នាទី

Scanned with CamScanner

រសៀលមកបេនអូរឡាំពិកចាប់បានម៉ូយប្រសៗ៣នាក់ ជិកមកដល់ជីភូម៉ោង ៥ជាង និងបាន ដាក់ម៉ូយនៅអូរាំងម្នាក់ រួចដាក់ម៉ូយម្នាក់ទៀតនៅកាស៊ីណូម៉ាការ និងចុង ក្រោយដាក់ម៉ូយម្នាក់ ទៀតនៅកាស៊ីណូម៉ុកបាយ និងវិលមកវិញចូលផ្សារជីភូទិញម្ហូប១០០០០ រៀល មកផ្ទះតែម្តង។ ចម្លើយដោះសាររបស់ជនជាប់ចោទខាងលើ ពុំមានមូលដ្ឋានពិតប្រាកដ ច្បាស់លាស់អាចឱ្យ តុលាការជឿបាននោះទេ ដោយគ្រាន់តែជាចម្លើយដោះសារតែប៉ុណ្ណោះ។

យល់ឃើញថា: ជនជាប់ចោទឈ្មោះ [redacted]ុជាតិ និងឈ្មោ[redacted]ូនី ជានីតិជន មានស្មារតីគ្រប់គ្រាន់នៅពេលប្រព្រឹត្តបទល្មើស គេពុំមានជម្ងឺវិបល្លាសស្មារតីទេ មានសមត្ថភាព ពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់ ។

យល់ឃើញថា: អំពើរបស់ជនជាប់ចោទទាំងពីរនាក់ដែលរួមគ្នាចាប់រំលោភសេព សន្ថវៈលើជនរងគ្រោះរួចរឹតកនិងកន្សែងសម្លាប់ជនរងគ្រោះនិងអូសយកទៅបោះចោលក្នុងទឹក ស្រែជាអំពើឃោឃៅព្រៃផ្សៃយង់ឃ្នងបំផុត វាបានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសណ្តាប់ ធ្នាប់ និងសន្តិសុខសង្គម ដែលក្រមព្រហ្មទណ្ឌត្រង់មាត្រា ២ និង ៣ បានហាមឃាត់ជាដាច់ខាត នឹងត្រូវផ្តន្ទាទោសតាមបញ្ញាតិច្បាប់ ។ ហើយអំពើនេះមានធាតុផ្សំគ្រប់គ្រាន់ពីបទ ឃាតកម្ម ដោយទារុណកម្ម រំលោភសេពសន្ថវៈ តាមបញ្ញាត្តិមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ ។

យល់ឃើញថា:សាលក្រមរបៀបលេខ ០៨(ឃ)ចុះថ្ងៃទី២៧ ខែ មេសា ឆ្នាំ ២០១៨ របស់សាលាដំបូងខេត្តស្វាយរៀង បានសម្រេចបង្គាប់ឱ្យមន្ត្រីជំនាញនៃស្នងការនគរបាលខេត្ត ស្វាយរៀង ធ្វើការស្រាវជ្រាវលើប្រពន្ធទូរស័ព្ទឈ្មោះ [redacted] សុជាតិ[redacted]និង ប្រពន្ធទូរស័ព្ទឈ្មោះ [redacted]ស្ងួនិ[redacted]និងលេខ [redacted] ឬប្រពន្ធ ទូរស័ព្ទផ្សេងតេមកចូលទំនាក់ទំនងឈ្មោះ [redacted] សុជាតិ ។ តែជាលទ្ធផលរបស់នាយកដ្ឋាន ប្រឆាំងបទល្មើសបច្ចេកវិទ្យាលេខ ៨៥៦ ន.ប.ប.ប ចុះថ្ងៃទី ០៦-០៦-២០១៨ បញ្ជាក់ថា ប្រពន្ធទូរ ស័ព្ទទាំង ៣ខាងលើ ក្រុមហ៊ុនមិនអាចផ្តល់មកឱ្យការិយាល័យជំនាញបានទេ ដោយក្រុមហ៊ុន រក្សាទិន្នន័យទូរស័ព្ទបានរយៈពេល ត្រឹមតែ ៩០ថ្ងៃប៉ុណ្ណោះ ។

យល់ឃើញថា:កំណត់ហេតុស្រាវជ្រាវនិងពិនិត្យកន្លែងកើតហេតុលេខ ១១/១៧ ក.ហ ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៧ របស់សមត្ថកិច្ចជំនាញអះអាងបញ្ជាក់ថា ជនរងគ្រោះ ស្លាប់ដោយអំពើឃាតកម្ម(រំលោភសម្លាប់) កាលពីថ្ងៃទី ០២-០៨-២០១៧ និងបានប្រគល់ សាកសពឱ្យទៅក្រុមគ្រួសារយកទៅធ្វើបុណ្យតាមប្រពៃណី ។

យល់ឃើញថា:ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ស្រីឡូត និងប្តី ឈ្មោះ [redacted]សុវណ្ណ និងចម្លើយសាក្សីឈ្មោះ[redacted]ចន្ទ មានមូលដ្ឋានអាចឱ្យតុលាការលើកយក មកពិនិត្យ ពិចារណាសម្រេចតាមច្បាប់ ។

យល់ឃើញថា:ចម្លើយសាក្សីដោះបន្ទុកឱ្យជនជាប់ចោទឈ្មោះ [redacted] ស្ងួនី គឺ ឈ្មោះ [redacted] សារុធ,ឈ្មោះ[redacted]ធឿន,ឈ្មោះ [redacted]យ៉ូន,ឈ្មោះ[redacted]ណាត,ឈ្មោះ[redacted]រ៉ាំង,ឈ្មោះ [redacted] សារិ,ឈ្មោះ[redacted]សារ៉ាន,ឈ្មោះ[redacted] សុខេង,ឈ្មោះ [redacted]ស៊ីភូន និងឈ្មោះ [redacted]តុលា ពុំមាន មូលដ្ឋានគ្រប់គ្រាន់ និងច្បាស់លាស់គួរឱ្យតុលាការជឿបានទេ ។

យល់ឃើញថា: ចម្លើយសាក្សីឈ្មោះ [redacted] សាមុត និងឈ្មោះ[redacted] សាវី មានមូល ដ្ឋានគួរឱ្យតុលាការលើកយកមកពិនិត្យពិចារណាសម្រេចតាមច្បាប់ ។

យល់ឃើញថា:សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេ ណី មានមូលដ្ឋានដែលអាចឱ្យតុលាការលើកយកមកពិនិត្យពិចារណាសម្រេចតាមច្បាប់ ។

យល់ឃើញថា:សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] សុជាតិ មានហេតុផលគ្រប់គ្រាន់ដែលអាចឱ្យតុលាការជឿនិងលើកមកពិនិត្យពិចារណា សម្រេចតាមច្បាប់ ។

យល់ឃើញថា:សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted]ូនី ពុំមានមូលដ្ឋានគួរឱ្យតុលាការជឿបានទេ ។

Scanned with CamScanner

<u>យល់ឃើញថា:</u>ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងពេលសវនាការប្ដឹងសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនល្មើសតាមច្បាប់ និងសុំទាមទារប្រាក់សំណងចំនួន ៦០ ០០០ដុល្លារអាមេរិក គប្បីតុលាការលើកមកពិនិត្យពិចារណានិង សម្រេចតាមច្បាប់ ។

<u>យល់ឃើញថា:</u>វត្ថុតាងរួមមាន: រថយន្តម៉ាក LEXUS RX 300ពណ៌ទឹកមាស ពាក់ស្លាកលេខ ភ្នំ ពេញ 2AL. 4238 ផលិតក្នុង២០០០ ដែលមានលេខម៉ាស៊ីន1MZ 1396838 និងលេខតួ JT6HF 10 U7Y0102473 និងចង្កឹះសោរចំនួន១ ត្រូវបានចៅក្រមស៊ើបសួរសម្រេចប្រគល់ឱ្យទៅលោ[redacted] សម្បត្តិ (មេធាវីការពារឱ្យជនជាប់ចោ[redacted] សូនី)ប្រើប្រាស់វិញរួចហើយតាមដីកាសម្រេចលេខ ១៨៥២ កត.ព្រទ/១៧ ចុះថ្ងៃទី ០៧-០៩-២០១៧ ដែលគប្បីតុលាការពិនិត្យពិចារណាសម្រេចតាមច្បាប់ ។ ដោយឡែករថយន្តម៉ាកហាយឡិនឌ័ ពណ៌សពាក់ស្លាកលេខភ្នំពេញ2AQ-0525 ចង្កឹះ សោររថយន្តចំនួន១,ខ្សែកកាឡៃ១ខ្សែ,ចិញ្ចៀនកាឡៃ១វង់មានដាំត្បូងពណ៌ស,ទូរស័ព្ទដៃចំនួន ២គ្រឿង,ខ្សែដៃប្លាកទីន១ខ្សែទម្ងន់ ៣៨៣លី(ទឹក៧), ចិញ្ចៀនត្រាមាស១វង់ទម្ងន់៣ជី(មាស៩៩៩),វ៉ាលីដាក់ខោអាវពណ៌ក្រហម១,អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ១(ផ្ដេក សូនី),ទូរស័ព្ទដៃ ម៉ាកអាយហ្វូនស៊ិចប្លីស១គ្រឿង ពណ៌ទឹកមាស និងទូរស័ព្ទដៃម៉ាកណូគា(អ៊ិនចុចពិល)ពណ៌ក្រហម១គ្រឿង គប្បីតុលាការពិនិត្យពិចារណាសម្រេចតាមច្បាប់ ។

<u>យល់ឃើញថា:</u> មានភស្តុតាងដាក់បន្ទុកនិងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោ[redacted]សុជាតិ និងឈ្មោះ [redacted] សូនី ពីបទ: ឃាតកម្មដោយមានទារុណកម្ម និងអំពើរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី ០២-០៨-២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ។

**តុលាការវិនិច្ឆ័យសេចក្ដី**

១-ផ្ដន្ទាទោសលើ

ក-ឈ្មោ[redacted]សុជាតិ ភេទ ប្រុស អាយុ ៣៥ឆ្នាំ

ខ-ឈ្មោះ [redacted]សូនី(ហៅមុន្នី) ភេទ ប្រុស អាយុ ៣២ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់ អស់មួយជីវិត ពីបទ: ឃាតកម្មដោយមានទារុណកម្ម និងអំពើរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី ០២-០៨-២០១៧ បទល្មើសព្រហ្មទណ្ឌដែលមាន ចែងឲ្យផ្ដន្ទាទោសតាមមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ[redacted] សុជាតិ និងឈ្មោះ[redacted]សូនី(ហៅមុន្នី) រួមគ្នាសងប្រាក់សំណងទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]សុវណ្ណ ចំនួន ៦០ ០០០(ប្រាំមួយម៉ឺន)ដុល្លារអាមេរិក ។

៣-វត្ថុតាងរួមមាន:

-រថយន្តម៉ាកហាយឡិនឌ័ពណ៌សពាក់ស្លាកលេខភ្នំពេញ2AQ-0525 និងទូរស័ព្ទដៃចំនួន ៤គ្រឿង ដែលបានដកហូតពីជនជាប់ចោទត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

-រថយន្តម៉ាក LEXUS RX 300ពណ៌ទឹកមាស ពាក់ស្លាកលេខ ភ្នំ ពេញ 2AL. 4238 ផលិតក្នុង២០០០ ដែលមានលេខម៉ាស៊ីន1MZ 1396838 និងលេខតួ JT6HF 10 U7Y0102473 និងចង្កឹះសោរចំនួន១ ត្រូវប្រគល់ឱ្យទៅម្ចាស់ដើមប្រើប្រាស់ជាកម្មសិទ្ធិវិញ ។

-ខ្សែកកាឡៃ១ខ្សែ,ចិញ្ចៀនកាឡៃ១វង់មានដាំត្បូងពណ៌សត្រូវប្រគល់ឱ្យទៅ

Scanned with CamScanner

ឈ្មោះ [redacted] ស្រីឡូត ដែលត្រូវជាម្តាយសពជនរងគ្រោះវិញ ។

-ខ្សែដៃប្លាកទីន១ខ្សែទម្ងន់ ៣៨៣លី(ទឹក៧), ចិញ្ចៀនត្រាមាស១វង់ ទម្ងន់៣ជី (មាស៩៩៩),វ៉ាលីដាក់ខោអាវពណ៌ក្រហម១,អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ [redacted] សូនី)ត្រូវប្រគល់ឱ្យទៅម្ចាស់ដើមវិញ ។

៨-សាលក្រមនេះជុំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ឈ្មោ[redacted] សុជាតិ,ឈ្មោះ [redacted] សូនី និងដើមបណ្តឹងរដ្ឋប្បវេណី ។

-បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ក្រុមប្រឹក្សាជំនុំជំរះ** | **ប្រធានក្រុមប្រឹក្សាជុំនុំជំរះ** |
|---|---|---|
| ហត្ថលេខាត្រា , | ហត្ថលេខាត្រា, ហត្ថលេខាត្រ័, | ហត្ថលេខាត្រា |
| ឈ្មោះ [redacted] | ឈ្មោះ [redacted] ,ឈ្មោះ [redacted] | ឈ្មោះ [redacted] |

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃច័ន្ទ១កើត ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅស្វាយរៀង ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៨
**ក្រឡាបញ្ជី**

[redacted]

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

[redacted]

Scanned with CamScanner